# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារ

កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារនេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី ០១ មិថុនា ២០២០ រវាង

**លោកស្រី ចាន់ ស៊ី** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១០១៥៣៤៦៣(០១) ដែលមានតួនាទីជា **នាយិកាគ្រប់គ្រងទូទៅ** និងជាតំណាងភាគីនិយោជក នៃក្រុមហ៊ុន **វើលដ៍ ដាយនីង លីមីធីត** ដែលមានអាសយដ្ឋានស្ថិតនៅ ផ្ទះ ២៨ ផ្លូវសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ និង

- **លោកស្រី ញាណ ផាន់ណារ៉ា** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១១១៨៣៥៣៣ ដែលមានតួនាទីជា **ប្រធានផ្នែកគ្រប់គ្រងភោជនីយដ្ឋាន** និងជាតំណាងភាគីនិយោជិក នៃក្រុមហ៊ុនខាងលើ។
- **លោក ចាប សារ៉ាក់** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១០៧៩៨៧១៩ ដែលមានតួនាទីជាប្រធានផ្នែកចុងភៅ និងជាតំណាងភាគីនិយោជិក នៃក្រុមហ៊ុនខាងលើ។

ភាគីទាំងពីរបានធ្វើការព្រមព្រៀងគ្នាដូចខាងក្រោម៖

**១៖ រយៈពេលនៃការព្យួរកិច្ចសន្យាការងារ៖**

ការព្យួរកិច្ចសន្យាការងារ ចាប់ពីថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២០ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ មូលហេតុដោយសារក្រុមហ៊ុនបានទទួលរងនូវផលប៉ះពាល់យ៉ាងអវិជ្ជមានលើផ្នែកហិរញ្ញវត្ថុ បង្កដោយវីរុស កូវីដ១៩។

**២៖ ប្រាក់ឈ្នួលកំឡុងពេលព្យួរកិច្ចសន្យាការងារ៖**

ភាគីនិយោជក មិនមានផ្តល់ជាប្រាក់ឧបត្ថម្ភអ្វីឡើយ ក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះ។

ភាគីនិយោជិក មិនទាមទារប្រាក់ឧបត្ថម្ភអ្វីឡើយ ពីនិយោជក ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ។

**៣៖ កាលបរិច្ឆេទចូលបម្រើការងារវិញ**

បុគ្គលិកនិយោជិកទាំងអស់ត្រូវត្រឡប់ចូលមកបម្រើការងារវិញ បន្ទាប់ពីរយៈពេលព្យួរកិច្ចសន្យាការងារនេះ ត្រូវបានបញ្ចប់។

កិច្ចសន្យានេះត្រូវបានធ្វើឡើងជាពីរ(០២)ច្បាប់ និងមានតម្លៃស្មើគ្នាចំពោះមុខច្បាប់ ដែលសម្រាប់ភាគីនីមួយៗទុកម្នាក់មួយ(០១)ច្បាប់។

ភាគីទាំងពីរបានអាន ព្រមព្រៀងគ្នា និងបានផ្តិតមេដៃ ដើម្បីជាសាក្សីភាព៕

រាជធានីភ្នំពេញថ្ងៃទី ០១ មិថុនា ២០២០

**តំណាងភាគីនិយោជិក**

លោកស្រី ញាណ ផាន់ណារ៉ា
អ្នកគ្រប់គ្រងភោជនីយដ្ឋាន

លោក ចាប សារ៉ាក់
ប្រធានចុងភៅ

**តំណាងភាគីនិយោជក**

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
វើលដ៍ ដាយនីង លីមីធីត
World Dining Limited
KINGDOM OF CAMBODIA

លោកស្រី ចាន់ ស៊ី
នាយិកាគ្រប់គ្រងទូទៅ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ម្ចាស់ ឬនាយកក្រុមហ៊ុនៈ វើលដ៍ ដាយនីង លីមីធីត**
លេខបញ្ជីពាណិជ្ជកម្មៈ ០០០០៣០៧៦
លេខអត្តសញ្ញាណសហគ្រាសក្នុង ប.ស.ស.៖ ១០០៧០៧៥
លេខគណនីធនាគារ៖ ០៥០-០២-១០-០០៩៧៩-១ (ធនាគារកម្ពុជាសាធារណៈ)
អាសយដ្ឋាន៖ លេខផ្ទះ លេខផ្លូវ 28 ភូមិ   ឃុំ/សង្កាត់ ទន្លេបាសាក់ ក្រុង/ស្រុក/ខណ្ឌ ចំការមន រាជធានី/ខេត្ត ភ្នំពេញ
ទូរស័ព្ទលេខ៖ ០៨១៦៦៨៨៨២   អ៊ីមែល (E-mail)៖ hr.payroll@almondgroup.biz

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**តាមរយៈ** ៖ លោកប្រធាននាយកដ្ឋានអធិការកិច្ចការងារ
**កម្មវត្ថុ** ៖ សំណើសុំព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតចំនួន ២៤នាក់ រយៈពេល ១៥ថ្ងៃ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដោយមូលហេតុក្រុមហ៊ុនយើងខ្ញុំខ្វះអតិថិជន ដូច្នេះក្រុមហ៊ុនយើងខ្ញុំស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ២៤នាក់ (ស្រី ១៣នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ១០០នាក់ (ស្រី ៤៧នាក់) រយៈពេល ១៥ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។

ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនបានព្រមព្រៀងផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតចំនួន.........................ដុល្លារអាមេរិក។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០២០
ហត្ថលេខា និងត្រា
ម្ចាស់ ឬនាយក

**សូមភ្ជាប់មកជាមួយ:**
- កិច្ចព្រមព្រៀងអំពីនីតិវិធីទូទាត់ជាមួយកម្មករនិយោជិតចំនួន ៣ច្បាប់
- បញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារចំនួន ៣ច្បាប់ និង ជា Soft Copy (Ms Excel) ទៅ E-mail: suspension@nea.gov.kh
- បញ្ជីបើកប្រាក់ឈ្នួលចុងក្រោយមុនពេលស្នើសុំព្យួរកិច្ចសន្យាការងារ
- វិញ្ញាបនបត្រពាណិជ្ជកម្ម (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់
- ប័ណ្ណពន្ធប៉ាតង់ (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់
- អាជ្ញាប័ណ្ណទេសចរណ៍ (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់ (វិស័យទេសចរណ៍)
- វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន ក្នុង ប.ស.ស. ចំនួន ៣ច្បាប់ (បើមាន)